00704168

E51/10/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 06 / 2011
ម៉ោង (Time/Heure): 15:51
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier No. 002/19-09-2007-ECCC/TC

ចំពោះមុខ: ចៅក្រម និល ណុន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១១
ភាសាដើម: ខ្មែរ/អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Andrew CAYLEY

**<u>ជនជាប់ចោទ</u>**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

00704169

E51/10/2

| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី** | **មេធាវីជនជាប់ចោទ** |
| --- | --- |
| ពេជ អង្គ<br>Elisabeth SIMONNEAU FORT | សុន អរុណ<br>Michiel PESTMAN<br>Victor KOPPE<br>អាង ឧត្តម<br>Michael G. KARNAVAS<br>ផាត់ ពៅសឹង<br>Diana ELLIS<br>សរ សូវ៉ាន<br>Jacques VERGÈS |

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")

**បានទទួល** សំណុំរឿងលេខ ០០២/១៩-៩-២០០៧-អវតក/អជសង អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានចេញដោយអង្គបុរេជំនុំជម្រះនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[១]។

**បានឃើញ** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១១ (E51/10/1) ("សំណើ") ដែលស្នើសុំពេលវេលាដប់ថ្ងៃបន្ថែមទៀតក្នុងការដាក់ឯកសារឆ្លើយតបរបស់ខ្លួនចំពោះសារណាបន្ថែមរបស់លោក អៀង សារី ("សារណាបន្ថែម") លើអញ្ញត្រកម្មតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១១ (ការលើកលែងទោស និងការអនុគ្រោះទោស) (E51/10) ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការបកប្រែ ដោយហេតុថាភាសាខ្មែរនៃសារណាត្រូវបានជូនដំណឹងនៅថ្ងៃទី ០៦ ខែ មិថុនាំ ឆ្នាំ២០១១។

[១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/1/26។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/4/14។ និងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តឋិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/5/9។

**យល់ឃើញថា** ការដាក់ឯកសារឆ្លើយតបនេះ ត្រូវធ្វើឡើងតាមឱកាសឆាប់រហ័សតាមដែលអាចធ្វើទៅបានដែលជាការចាំបាច់ចំពោះការរៀបចំសវនាការបឋមឱ្យទាន់តាមពេលវេលា។

**កត់សម្គាល់** អំពីមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វ.០៦ ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១ (E38) ដែលអនុញ្ញាតឱ្យភាគីណាមួយដាក់ឯកសារតែមួយភាសាការងារនៃ អ.វ.ត.ក បានក្នុងករណីដែលភាគីមិនអាចដាក់ភាសាខ្មែរ និងភាសាអង់គ្លេស និង/ឬភាសាបារាំងទៅតាមកាលបរិច្ឆេទកំណត់។

**កត់សម្គាល់ឃើញថា** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានទទួលការជូនដំណឹងអំពីសារណាបន្ថែមរបស់ អៀង សារី នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១។

## ហេតុដូច្នេះសម្រេច

**ផ្តល់ជូន** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរយៈពេលបន្ថែមមួយថ្ងៃដើម្បី ដាក់ឯកសារឆ្លើយតបរួមមួយទៅនឹងសារណាបន្ថែមរបស់អៀង សារី ពោលគឺរហូតដល់ថ្ងៃស្អែក (ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១) ជាភាសាខ្មែរ និងបារាំង ឬតែជាភាសាខ្មែរ ឬភាសាបារាំងតែមួយ (ដោយដាក់អត្ថបទបកប្រែតាមក្រោយ)។

**បដិសេធ** សំណើសុំបន្ថែមពេលវេលាដប់ថ្ងៃ។

**ក្រើនរំលឹក** ដល់គ្រប់ភាគីទាំងអស់ថា ភាគីដែលដាក់សំណើសុំបន្ថែមពេលវេលាបន្ទាប់ពីផុតពេលកំណត់នោះ មិនប្រាកដថា អាចទទួលបានការអនុញ្ញាតដោយអង្គជំនុំជម្រះឡើយ។

ភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER · CHAMBRE DE PREMIERE INSTANCE · E.C.C.C.

និល ណុន